**តុលាការកំពូល និងមហាអយ្យការ**
**អមតុលាការកំពូល**
លេខ ២៣០.តកក.-២០០៦

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

## ប្រធានតុលាការកំពូល

**ជម្រាបមក**

**លោក លោកស្រី ជាចៅក្រម**

**ព្រះរាជអាជ្ញា ព្រះរាជអាជ្ញារង ទាំងអស់**

***សូមជ្រាប។***

**កម្មវត្ថុ:** អំពីការសម្រេចមុនអង្គសេចក្ដីក្នុងរឿងព្រហ្មទណ្ឌ

ខ្ញុំសូមជម្រាបលោក លោកស្រីថា កន្លងមកតុលាការកំពូលសង្កេតឃើញថា សេចក្ដីសម្រេចមុនអង្គសេចក្ដីក្នុងរឿងព្រហ្មទណ្ឌរបស់តុលាការខេត្ត-ក្រុង និងអយ្យការអមតុលាការខេត្ត-ក្រុងមួយចំនួនដូចជា ដីកាតម្កល់រឿងទុកមិនចាត់ការ ដីកាឱ្យនៅក្រៅឃុំជាបណ្ដោះអាសន្ន ពិសេសដីការលើកលែងចោទប្រកាន់ ច្រើនធ្វើឡើងដោយពុំមានសំអាងហេតុត្រឹមត្រូវ ឬ ពុំមានសំអាងហេតុណាមួយទាល់តែសោះ ។

ខ្ញុំសូមរំលឹកលោក លោកស្រីថា តាមគោលការណ៍ច្បាប់រាល់សេចក្ដីសម្រេចទាំងអស់ ត្រូវតែមានសំអាងហេតុ ។ សំអាងហេតុត្រូវតែច្បាស់លាស់ និងគ្រប់ចំណុចសំខាន់ៗបញ្ជាក់នូវគំនិតរបស់ចៅក្រមដែលមិនអាចឱ្យមានការភ័ន្តច្រឡំនោះឡើយ ។

អាស្រ័យហេតុនេះ ខ្ញុំសូមលោក-លោកស្រីជាចៅក្រម ជាព្រះរាជអាជ្ញា ព្រះរាជអាជ្ញារងទាំងអស់យកចិត្តទុកដាក់ឱ្យបានហ្មត់ចត់ក្នុងការសរសេរសំអាងហេតុ ដោយលើកបទបញ្ញត្តិច្បាប់ជាធរមានជាបង្អែកនិងសំណូមពរដល់លោកប្រធានតុលាការត្រួតពិនិត្យឱ្យបានដិតដល់នូវដីការទាំងអស់នេះមុននឹងបញ្ជូនចេញ ។

សូមលោក-លោកស្រី ទទួលនូវការរាប់អានដ៏ស្មោះស្ម័គ្រពីខ្ញុំ ។

ធ្វើនៅភ្នំពេញ ថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០០៦

**ឌិត មុន្ទី**